# របាយការណ៍ប្រចាំឆ្នាំ

ខែឧសភា ឆ្នាំ២០១៧ - ខែមិថុនា ឆ្នាំ២០១៨

Better Factories Cambodia

## គន្លឹះសំខាន់ៗពាក់ព័ន្ធនឹងបញ្ហាសុខភាព និងសុវត្ថិភាពការងារ (OSH)

កម្រងសំណួរ OSH ទាំង៦៨

រោងចក្រចំនួន ៤៦៤ ដែលបានវាយតម្លៃ

កម្មករនិយោជិតសរុប ៦០២.៦០៧

## ចំណុចកែលំអ

### ការត្រៀមបង្ការពេលមានអាសន្ន

ត្រូវធានាថា ផ្លូវសម្រាប់រត់ចេញពីអគាររោងចក្រ ពុំមានអ្វីរាំងស្ទះ

ត្រូវមានប្រព័ន្ធផ្តល់សញ្ញាអគ្គីភ័យ និងកន្ទឹងបន្លឺសំលេង ពេលមានអាសន្នដែលមានដំណើរការល្អ

អនុវត្តនូវការហ្វឹកហាត់រត់ជម្លៀសពេលមានអាសន្ន ឲ្យបានទៀតទាត់ដើម្បីធានាថា កម្មករនិយោជិតបានយល់ដឹង និងអាចដឹងថាត្រូវជម្លៀសខ្លួនទៅណានៅពេលដែលមានអាសន្ន

ត្រូវធានាថា រាល់ប្រភពដែលអាចបង្កឲ្យមានការឆាបឆេះ គឺត្រូវបានគ្រប់គ្រង និងត្រួតពិនិត្យប្រកបដោយសុវត្ថភាព

### សុវត្ថិភាពផ្នែកសារធាតុគីមី

រាល់សារធាតុគីមីដែលបង្កឲ្យមានគ្រោះថ្នាក់ទាំងអស់ គឺត្រូវតែមានបិតស្លាកសញ្ញាជាភាសាខ្មែរត្រឹមត្រូវ

និយោជក ត្រូវធានាថា កម្មករនិយោជិតទាំងអស់ ទទួលបានការបណ្តុះបណ្តាលបានត្រឹមត្រូវពាក់ព័ន្ធទៅនឹងការងារដែលប៉ះពាល់ជាមួយនឹងសារធាតុគីមី

បញ្ហាជាច្រើនដែលពាក់ព័ន្ធទៅនឹងសុខភាព និងសុវត្ថិភាពការងារ(OSH) គឺនៅតែជាបញ្ហាប្រឈមនៅឡើយនៅក្នុងរោងចក្រកាត់ដេរសំលៀកបំពាក់ ហើយជាលទ្ធផលបានបង្ហាញពីកង្វះខាតនៃគោលនយោបាយនិតិវិធី និងទំនួលខុសត្រូវច្បាស់លាស់ចំពោះបញ្ហាសុខភាព និងសុវត្ថិភាពការងារ

## តើអ្វីទៅជាប្រព័ន្ធគ្រប់គ្រងបញ្ហាសុខភាព និងសុវត្ថិភាពការងារ?

និតិវិធី យន្តការ គោលការណ៍ណែនាំ និងគោលនយោបាយ ដែលមានលក្ខណៈជាប្រព័ន្ធ ដើម្បីជួយសម្រួលដល់ការងារក្នុងរោងចក្រ និងកម្មករនិយោជិត ឲ្យអនុវត្តបានត្រឹមត្រូវពាក់ព័ន្ធនឹងបញ្ហាសុខភាព និង សុវត្ថិភាពការងារ ចំពោះកិច្ចការ ដែលកម្មករនិយោជិតធ្វើជារៀងរាល់ថ្ងៃ។

## តើមានរោងចក្រចំនួនប៉ុន្មានដែលបានអនុវត្តត្រឹមត្រូវ ចំពោះប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារ?

- ចំនួនរោងចក្រដែលអនុត្តតាមលក្ខខណ្ឌ
- ចំនួនរោងចក្រដែលមិនងបានអនុត្តតាមលក្ខខណ្ឌ




តើនិយោជកមានការទទួលខុសត្រូវ ក្នុងការគ្រប់គ្រងបញ្ហាសុខភាព និង សុវត្ថិភាពការងារបានត្រឹមត្រូវ ហើយឬនៅ?




តើនិយោជកបានទំនាក់ទំនង និងអនុវត្តគោលការណ៍ និងនិតិវិធីនៃបញ្ហាសុខភាព និង សុវត្ថិភាពការងារហើយឬនៅ?




តើនិយោជកបាន ស៊ើបអង្កេត ត្រួតពិនិត្យ និងវាយតម្លៃ ហើយឬនៅអំពីបញ្ហាសុខភាព និងសុវត្ថិភាពការងារ ដើម្បីកំណត់ដើមហេតុនៃបញ្ហា ហើយចាត់វិធានការកុំឲ្យមាន ហេតុការណ៍នេះកើតឡើង?




តើរោងចក្រមាននិតិវិធីក្នុងការ ស៊ើបអង្កេតរកបញ្ហាឲ្យបាន គ្រប់គ្រាន់ដែរឬទេ?




តើរោងចក្រមាននិតិវិធីត្រៀម បង្ការពេលមានអាសន្ន បានគ្រប់គ្រាន់ហើយឬនៅ?




តើរោងចក្រមាននិតិវិធីក្នុងការ ត្រួតពិនិត្យនិងគ្រប់គ្រងគ្រោះថ្នាក់ផ្សេងៗ និងហានិភ័យបាន គ្រប់គ្រាន់ដែរឬទេ?

| ចំនួនសំណួរពីប្រព័ន្ធគ្រប់គ្រង | 0 | 1 | 2 | 3 | 4 | 5 | 6 |
|---|---|---|---|---|---|---|---|
| ចំនួនរោងចក្រ | 163 | 92 | 62 | 56 | 38 | 30 | 23 |




**អ្វីដែលបានបង្ហាញនេះ គឺរោងចក្រដែលមានប្រព័ន្ធគ្រប់គ្រងល្អ មានទំនាក់ទំនងយ៉ាងខ្លាំងនូវភាពប្រសើរចំពោះសុខភាព និងសុវត្ថិភាពការងារ ហើយក៏ទទួលបាន កម្រិតអនុលោមតាមលក្ខខណ្ឌការងារទូទៅបានល្អទៅតាមច្បាប់ការងារផងដែរ**

- ភាគរយទូទៅនៃរោងចក្រដែលពុំមានភាពអនុលោម
- ភាគរយនៃកម្រងសំនួរដែលពុំមានភាពអនុលោម នៃបញ្ហាសុខភាព និងសុវត្ថិភាពការងារ (OSH)